King County

Department of Community and Human Services
Mental Health, Chemical Abuse and Dependency Services Division
Chinook Building, CNK-HS-0400
401 Fifth Avenue, Suite 400
Seattle, WA 98104
206 263-9000 TTY/TDD: 206-205-0569
www.kingcounty.gov/healthServices/MHSA

# សេចក្តីប្រកាសខាងការអនុវត្តន៍រក្សាជាភាពឯកជន/សម្ងាត់

ផ្នែកខាងកិច្ចបំរើសុខភាពខាងខួរក្បាលឬប្រាជ្ញាចិត្ត, ការប្រមាថនិងការពឹងផ្អែកទៅលើគ្រឿងញៀន/ស្រវឹងប្រចាំតំបន់ឃីង
ផែនការសុខភាពខាងផ្នែកខួរក្បាលឬប្រាជ្ញាចិត្ត

*ថ្ងៃចាប់ប្រតិបត្តិ: ១៤ មេសា, ២០០៣*

## សេចក្តីប្រកាសនេះពិពិណនាអំពីរបៀបដែលគេអាចប្រើប្រាស់និងបញ្ចេញពិតមានសុខភាពលោកអ្នកនិងពីរបៀបដែលលោកអ្នកអាចទៅយកពិតមាននេះមកប្រើប្រាស់បាន។

## <u>សូមពិនិត្យពិតមាននេះសារជាថ្មីដោយយកចិត្តទុកដាក់</u>

ផ្នែកខាងកិច្ចបំរើសុខភាពខាងខួរក្បាលឬប្រាជ្ញាចិត្ត, ការប្រមាថនិងការពឹងផ្អែកទៅលើគ្រឿងញៀន/ស្រវឹងប្រចាំតំបន់ឃីង (MHCADSD) គោរពចំពោះភាពជាឯកជន/សម្ងាត់របស់លោកអ្នក។ យើងយល់ថាពិតមានអំពីសុខភាពផ្ទាល់ខ្លួនរបស់លោកអ្នកជាពិតមានដែលងាយប្រែក្រឡាប់ខ្លាំងណាស់។យើងនឹងមិនបញ្ចេញឲ្យនរណាដឹងពីពិតមានអំពីសុខភាពរបស់លោកអ្នកទេលុះត្រាតែលោកអ្នកអនុញ្ញាត ឬក៏ច្បាប់ប្រគល់អំណាចឬតម្រូវឲ្យយើងធ្វើការនោះដែរ។

## I. សទ្ធិគ្រប់គ្រងលើពិតមានអំពីសុខភាពរបស់លោកអ្នក

យើងនឹងមានឯកសារដែលស្តីអំពីសុខភាពរបស់លោកអ្នក។ លោកអ្នកមានសិទ្ធិដែលទាក់ទងទៅនឹងពិតមាននេះ រាប់បញ្ចូលទាំងសិទ្ធិនៅក្នុងការ:

- ធ្វើសំណើក្នុងការដាក់កំរិតលើពិតមានអំពីសុខភាពរបស់លោកអ្នកដែលយើងប្រើប្រាស់ឬបញ្ចេញសំរាប់ការព្យាបាល, ការចេញថ្លៃសំរាប់ការព្យាបាល, កិច្ចប្រតិបត្តិការថែទាំសុខភាពរបស់លោកអ្នក។ លោកអ្នកត្រូវតែផ្តល់នូវសំណើនេះជាលាយល័ក្ខអក្សរមកភ្នាក់ងាររក្សាជាភាពឯកជន/សម្ងាត់នៅឯការិយាល័យយើង។ភ្នាក់ងាររក្សាជាភាពឯកជន/សម្ងាត់នេះនឹងសុំឲ្យលោកអ្នកចុះហត្ថលេខាលើក្រដាស់បំពេញធ្វើការស្នើសុំការដាក់កំរិតដែលលោកអ្នកគួរតែបំពេញហើយផ្ញើរទៅភ្នាក់ងាររក្សាជាភាពឯកជន/សម្ងាត់នេះ។ យើងមិនតម្រូវឲ្យយល់ស្របនឹងកំរិតដែលលោកអ្នកស្នើសុំដាក់នោះទេ។

- លប់ចោលមុនការយល់ព្រមឲ្យប្រើប្រាស់ឬបញ្ចេញនូវពិតមានអំពីសុខភាពដោយផ្តល់នូវសេចក្តីប្រកាសជាលាយល័ក្ខអក្សរ។ យើងមានក្រដាសបំពេញសំរាប់ផ្តល់លោកអ្នកប្រើប្រាស់សំរាប់ការនេះ។ ការលប់ចោលរបស់លោកអ្នកមិនមានឥទ្ធិពលទៅលើពិតមានដែលលោកអ្នកបានបញ្ចេញរួចហើយនោះទេ។ ហើយវាក៏មិនមានឥទ្ធិពលទៅលើសកម្មភាពដែលបានកើតឡើងមុនយើងទទួលការលប់ចោលជាលាយល័ក្ខអក្សរនោះឡើយ។

King County

Department of Community and Human Services
Mental Health, Chemical Abuse and Dependency Services Division
Chinook Building, CNK-HS-0400
401 Fifth Avenue, Suite 400
Seattle, WA 98104
206 263-9000 TTY/TDD: 206-205-0569
www.kingcounty.gov/healthServices/MHSA

សេចក្តីប្រកាសខាងការអនុវត្តន៍រក្សាផាភាពឯកជន/សម្ងាត់"Notice of Privacy Practices"ខាងក្រោមនេះមានពិតមានសំខាន់ៗដែលស្តីអំពីរបៀបដែលផែនការសុខភាពខាងផ្នែកខួរក្បាលឬប្រាជ្ញាចិត្តប្រចាំតបន់ឃុំង King County Mental Health Plan ប្រើប្រាស់នឹងការពារ ឯកសារខាងផ្នែកសុខភាពខួរក្បាលឬប្រាជ្ញាចិត្ត។ នេះគឺជាសេចក្តីប្រកាសជាលាយល័ក្ខអក្សរដែលគេបានជូន មកលោកអ្នកដើម្បីអនុវត្តតាមច្បាប់ថ្មីមួយហៅថា ហ៊ីពផា HIPAA។[១]

I. ផ្នែកទី១ នៃសេចក្តីប្រកាសខាងការអនុវត្តន៍រក្សាផាភាពឯកជន/សម្ងាត់ពន្យល់អំពីសិទ្ធិផ្សេងៗដែលទាក់ទងទៅនឹងឯកសារសុខភាពរបស់លោកអ្នក។

II. ផ្នែកទី២ ជំរាបលោកអ្នកអំពីករណីយកិច្ចផ្សេងៗដែលផែនការសុខភាពខាងផ្នែកខួរក្បាលឬប្រាជ្ញាចិត្តប្រចាំតំបន់ឃុំងមានក្នុងការរក្សារទុកនូវឯកសារសុខភាពរបស់លោកអ្នកជាសម្ងាត់ និងជូនមកលោកអ្នកនូវក្រដាស់ថតចម្លងនៃសេចក្តីប្រកាសមួយ។

III. ផ្នែកទី៣ ពន្យល់អំពីរបៀបដែលផែនការសុខភាពខាងផ្នែកខួរក្បាលឬប្រាជ្ញាចិត្ត អាចប្រើប្រាស់និងចែកចាយនូវឯកសារសុខភាពលោកអ្នកសំរាប់ធ្វើការព្យាបាល, ការចេញថ្លៃ ការព្យាបាលរបស់លោកអ្នក និងសំរាប់មូលហេតុផ្សេងៗឯទៀត។

IV. ផ្នែកទី៤ ពន្យល់អំពីរបៀបដែលលោកអ្នកអាចសុំជំនួយដើម្បីពន្យល់ឲ្យបានយល់អំពីសិទ្ធិផ្សេងៗ ឬធ្វើការតវ៉ាអំពីការអនុវត្តន៍ខាងការរក្សាផាភាពឯកជន/សម្ងាត់។

សូមមើលទៅសេចក្តីប្រកាសនេះដើម្បីឲ្យបានដឹងពិតមានពេញលេញផាបន្ថែម។

9 Health Insurane Portability and Accountability Act

- ទទួលក្រដាសថតចម្លងនៃសេចក្តីប្រកាសខាងការអនុវត្តន៍រក្សាជាភាពឯកជន/សម្ងាត់សំរាប់ព័ត៌មានសុខភាពដែលមានការការពារ (" សេចក្តីប្រកាស" )ពីយើង។

- ធ្វើសំណើឲ្យលោកអ្នកពិនិត្យមើលនិងទិញក្រដាសថតចម្លងឯកសារអំពីសុខភាពរបស់លោកអ្នក។ លោកអ្នកត្រូវតែធ្វើការស្នើសុំនេះជាលាយល័ក្ខអក្សរ។ យើងមានក្រដាសបំពេញសំរាប់ប្រភេទនៃការស្នើសុំនោះ។ ប្រសិនបើជាការស្នើសុំរបស់លោកអ្នកត្រូវគេបដិសេធលោកអ្នកអាចតវ៉ាអំពីការបដិសេធនោះ(សុំឲ្យយើងពិនិត្យមើលសារជាថ្មីឡើងវិញ)។ ការតវ៉ានេះត្រូវតែសរសេរជាលាយល័ក្ខអក្សរ។

- ធ្វើសំណើឲ្យយើងកែប្រែព័ត៌មានអំពីសុខភាពណាមួយរបស់លោកអ្នកដែលគេប្រើប្រាស់នៅក្នុងការធ្វើការសំរេចអំពីការថែទាំសុខភាពរបស់លោកអ្នករាប់បញ្ចូលទាំងឯកសារអំពីការព្យាបាលឬឯកសារនៃការចេញថ្លៃការព្យាបាល។ ដើម្បីធ្វើការនេះបានលោកអ្នកដាក់ពាក្យសុំជាលាយល័ក្ខអក្សរទៅផ្នែកងាររក្សាជាភាពឯកជន/សម្ងាត់នៅ 401 Fifth Avenue, Suite 400, Seattle, WA 98104 ហើយប្រាប់ឲ្យយើងដឹងថាតើមូលហេតុអ្វីបានជាលោកអ្នកជឿជាក់ថាព័ត៌មាននេះមិនត្រឹមត្រូវ។ យើងអាចបដិសេធចំពោះសំណើឲ្យកែប្រែរបស់លោកអ្នកបានបើសិនមិនមែនជាសំណើជាលាយល័ក្ខអក្សរឬមិនបានដាក់បញ្ចូលនូវមូលហេតុដើម្បីគាំទ្រដល់សំណើនោះ។ យើងក៏អាចបដិសេធចំពោះសំណើរបស់លោកអ្នកបានដែរ បើសិនលោកអ្នកសុំឲ្យយើងកែប្រែព័ត៌មានអំពីសុខភាពដែល:

  - យើងមិនបានបង្កើត ឬលុះណាតែមនុស្សឬអង្គភាពដែលបង្កើតព័ត៌មានអំពីសុខភាពនោះលែងមានលទ្ធភាពកែប្រែបានទៀតហើយ
  - មិនមែនជាផ្នែកនៃព័ត៌មានអំពីសុខភាពដែលយើងរក្សាទុកដើម្បីសំរាប់ធ្វើការសំរេចអំពីការថែទាំសុខភាពរបស់លោកអ្នក
  - មិនមែនជាផ្នែកនៃព័ត៌មានអំពីសុខភាពដែលលោកអ្នកបានទទួលការអនុញ្ញាតឲ្យពិនិត្យមើលឬថតចម្លងឬក៏
  - ត្រឹមត្រូវនិងពេញលេញ។

- បើយើងបដិសេធចំពោះសំណើរបស់លោកអ្នកដើម្បីកែប្រែព័ត៌មានអំពីសុខភាពរបស់លោកអ្នក យើងនឹងផ្ញើរសេចក្តីប្រកាសជាលាយលក្ខអក្សរមួយសន្លឹកដែលថ្លែងអំពីមូលហេតុនៃការបដិសេធនោះហើយផ្តល់មកលោកអ្នកនូវឱកាសដើម្បីផ្តល់នូវសេចក្តីថ្លែងជាលាយល័ក្ខអក្សរជំទាស់នឹងការបដិសេធនោះ។ បើសិនលោកអ្នកមិនចង់រៀបចំធ្វើសេចក្តីថ្លែងអំពីការជំទាស់ជាលាយលក្ខអក្សរទេ លោកអ្នកអាចសុំឲ្យមានការកែប្រែដែលបានស្នើសុំនេះនិងការបដិសេធរបស់យើងនឹងមានដាក់ភ្ជាប់មកជាមួយនឹងការបញ្ចេញឲ្យដឹងព័ត៌មានអំពីសុខភាពដែលលោកអ្នកធ្វើការស្នើសុំនៅពេលអនាគត។ បើសិនលោកអ្នកជ្រើសរើសដាក់នូវសេចក្តីថ្លែងជំទាស់ជាលាយល័ក្ខអក្សរ យើងមានសិទ្ធិរៀបចំធ្វើការឆ្លើយតបដើម្បីលុបលាងជាលាយល័ក្ខអក្សរចំពោះសេចក្តីថ្លែងជំទាស់របស់លោកអ្នកវិញ។ នៅក្នុងករណីយនេះយើងនឹងភ្ជាប់មកជាមួយនូវសំណើនិងការឆ្លើយតបលុបលាងជាលាយល័ក្ខអក្សរ(ព្រមទាំងសំណើនិងការបដិសេធដើមដែរ)ទៅនឹងការបញ្ចេញឲ្យដឹងព័ត៌មានអំពីសុខភាពទាំងអស់ដែលលោកអ្នកធ្វើការស្នើសុំនៅពេលអនាគត។

- ធ្វើសំណើដែលយើងផ្តល់មកលោកអ្នកជាមួយនឹងបញ្ជីរនៃព័ត៌មានដែលត្រូវបញ្ចេញឲ្យដឹងដែលយើងបានយកពីព័ត៌មានអំពីសុខភាពរបស់លោកអ្នកតាំងពីថ្ងៃទី១៤ខែមេសាឆ្នាំ២០០៣មក។ បញ្ជីរគឺជាតារាងរាយឈ្មោះព័ត៌មានដែលត្រូវបញ្ចេញឲ្យដឹង។ ប៉ុន្តែតារាងនេះនឹងមានដាក់បញ្ចូលនូវការបញ្ចេញឲ្យដឹងជាក់លាក់ណាមួយនៃព័ត៌មានអំពីសុខភាពដូចព័ត៌មានដែលបានបញ្ចេញសំរាប់ការព្យាបាល, ការចេញថ្លៃការព្យាបាលនិងកិច្ចប្រតិបត្តិការថែទាំសុខភាពឬសំរាប់ការបញ្ចេញឲ្យដឹងដែលលោកអ្នកអនុញ្ញាតឲ្យបញ្ចេញជាលាយល័ក្ខអក្សរ។ ដើម្បីស្នើសុំនូវបញ្ជីររាយឈ្មោះព័ត៌មានសំរាប់បញ្ចេញលោកអ្នកត្រូវតែដាក់សំណើរបស់លោកអ្នកជាលាយល័ក្ខអក្សរទៅផ្នែកងាររក្សាជាភាពឯកជន/សម្ងាត់នៅឯការិយាល័យយើង។ ដើម្បីឲ្យមានការងាយស្រួលដល់លោកអ្នកៗអាចដាក់សំណើរបស់លោកអ្នកលើក្រដាសបំពេញដែលហៅថា "សំណើសំរាប់សុំបញ្ជីរ" "Request For Accounting" ដែលលោកអ្នកអាចទៅយកពីផ្នែកងាររក្សាជាភាពឯកជន/សម្ងាត់របស់យើងបាន។

- សុំឲ្យយើងធ្វើការប្រស្រ័យទាក់ទងជាមួយនឹងលោកអ្នកអំពីរឿងការថែទាំសុខភាពតែនៅទីកន្លែងឬតាមវិធីជាក់លាក់ណាមួយ។ ក្នុងការស្នើសុំការប្រស្រ័យទាក់ទងដែលរក្សាជាសម្ងាត់លោកអ្នកត្រូវតែឲ្យមកយើងនូវសំណើនោះជាលាយល័ក្ខអក្សរចុះហត្ថលេខានិងដាក់ថ្ងៃទីនៅលើសំណើនោះ។ លោកអ្នកអាចដាក់សំណើលើក្រដាសបំពេញរបស់យើងឬនៅក្នុងសំបុត្រដោយដាក់ព័ត៌មានទាំងអស់ដែលមាននៅលើក្រដាស

ចំពេញនោះ។ យើងនឹងបំពេញទៅតាមសេចក្តីត្រូវការចំពោះសំណើសមរម្យទាំងអស់។ លោកអ្នកមិនត្រូវការផ្តល់នូវមូលហេតុមកយើងទេក្នុងការដាក់សំណើ ក៏ប៉ុន្តែនៅក្នុងសំណើនោះលោកអ្នកត្រូវដាក់ឲ្យបានច្បាស់ជាក់លាក់ពីរបៀបឬកន្លែងដែលលោកអ្នកចង់ឲ្យគេទាក់ទងនឹងលោកអ្នក។

## II. ករណីយកិច្ចរបស់ផ្នែកចំរើខាងសុខភាពខួរក្បាលឬប្រាជ្ញាចិត្ត, ការប្រមាថនិងការពឹងផ្អែកទៅលើគ្រឿងស្រវឹង/ញៀន

ច្បាប់បានតម្រូវឲ្យយើង:

- រក្សានូវពត៌មានអំពីសុខភាពរបស់លោកអ្នកជាសម្ងាត់លើកលែងតែបានប្រាប់ឲ្យដឹងដូចខាងក្រោមនេះ:
- ឲ្យមកលោកអ្នកនូវសេចក្តីប្រកាសនេះនៅពេលលោកអ្នកស្នើសុំ
- ធ្វើតាមលក្ខ័ណនៃសេចក្តីប្រកាសខាងការអនុវត្តន៏រក្សាជាភាពឯកជន/សម្ងាត់ដែលកំពុងប្រតិបត្តិនៅពេលបច្ចុប្បនកាលនេះ។

  យើងមានសិទ្ធិផ្លាស់ប្តូរការអនុវត្តន៏របស់យើងដែលទាក់ទងនឹងពត៌មានអំពីសុខភាពដែលនៅក្រោមករការពារហើយដែលយើងរក្សាទុក។ បើសិនយើងធ្វើការផ្លាស់ប្តូរ យើងនឹងជូនដំណឹងថ្មីៗមកលោកអ្នកតាមសេចក្តីប្រកាសនេះ។ លោកអ្នកអាចទទួលនូវក្រដាសចម្លងនៃសេចក្តីប្រកាសនេះដែលមានពត៌មានថ្មីៗបំផុតដោយទូរស័ព្ទសុំសេចក្តីប្រកាសនេះឬក៏ទៅយកក្រដាសថតចម្លងនៃសេចក្តីប្រកាសនេះនៅការិយាល័យយើង។ លោកអ្នកអាចរកឃើញនូវសេចក្តីប្រកាសនេះនៅលើបណ្តាញនៃការទាក់ទងតាមកុំព្យូទ័ Web Page ដែលមានអាស័យដ្ឋាន www.kingcounty.gov/healthServices/MHSA

## III. តើយើងប្រើប្រាស់ឬបញ្ចេញពត៌មានដែលទាក់ទងខាងផ្នែកពេទ្យរបស់លោកអ្នកដោយវិធីណា

ប្រភេទខាងក្រោមនេះពិពណ៌នាអំពីវិធីដែលយើងប្រើប្រាស់និងបញ្ចេញពត៌មានអំពីសុខភាពរបស់យើង(រាប់បញ្ចូលទាំងសុខភាពខួរក្បាលឬប្រាជ្ញានិងរូបកាយ)។ សំរាប់ការប្រើប្រាស់និងបញ្ចេញពត៌មាននៃប្រភេទនិមួយៗ យើងនឹងពន្យល់អំពីអត្ថន័យរបស់យើងនិងឲ្យឧទាហរណ៏ដែរ។មិនមែនគ្រប់ទាំងការប្រើប្រាស់ឬការបញ្ចេញពត៌មាននៅក្នុងប្រភេទមួយនឹងមានសរសេរកត់ទុកនៅក្នុងបញ្ជីរទេ។ យ៉ាងណាមិញគ្រប់ទាំងរបៀបដែលគេអនុញ្ញាតឲ្យយើងប្រើប្រាស់និងបញ្ចេញពត៌មាននឹងធ្លាក់នៅក្នុងប្រភេទមួយក្នុងចំណោមប្រភេទនានា។

### ឧទាហរណ៏នៃការប្រើប្រាស់និងបញ្ចេញពត៌មានសំរាប់ការព្យាបាល, ការចេញថ្លៃការព្យាបាល និងកិច្ចប្រតិបត្តិការថែទាំសុខភាព

*សំរាប់ការព្យាបាល:*

- ពត៌មានដែលអ្នកផ្តល់ការថែទាំសុខភាពពរបស់លោកអ្នកបានទទួលនឹងត្រូវបានគេសរសេរកត់ទុកនៅក្នុងបញ្ជីរព្យាបាលសុខភាពរបស់លោកអ្នកនឹងត្រូវបានគេប្រើប្រាស់សំរាប់ធ្វើការសំរេចថាតើការថែទាំសុខភាពណាមួយដែលត្រឹមត្រូវសំរាប់លោកអ្នក។
- យើងអាចផ្តល់ពត៌មានបានដែរទៅវេជ្ជបណ្ឌិតឯទៀតឬអ្នកឯកទេសខាងថែទាំសុខភាពដែលចូលរួមក្នុងការថែទាំសុខភាពរបស់លោកអ្នក។

*សំរាប់ការចេញថ្លៃឲ្យការព្យាបាល:*

- យើងស្នើសុំការចេញថ្លៃឲ្យការព្យាបាលពីក្រសួងសង្គមកិច្ចនិងសុខមាលភាពប្រចាំរដ្ឋវ៉ាស៊ីនតោន (DSHS)។ ដើម្បីឲ្យមានសេចក្តីយល់ព្រមឲ្យមានការចេញថ្លៃឲ្យការព្យាបាល ក្រសួងសង្គមកិច្ចនិងសុខមាលភាពត្រូវការពត៌មានផ្សេងៗដូចជាការពិនិត្យមើលព្យាបាល, កិច្ចបំរើផ្សេងៗដែលគេបានផ្តល់ ឬការថែទាំសុខភាពដែលគេធ្វើសំណូមពរឲ្យធ្វើ។

*សំរាប់កិច្ចប្រតិបត្តិការថែទាំសុខភាព:*

- សមាជិកនៃបុគ្គលិករបស់យើងតែងតែពិនិត្យមើលឯកសារឡើងវិញជាធម្មតាដើម្បីធ្វើការប្រមាណមើលនូវគុណភាពនិងដើម្បីធ្វើឲ្យកិច្ចបំរើផ្សេងៗដែលយើងផ្តល់មកលោកអ្នកបានកាន់តែប្រសើឡើង។

## ការបញ្ចេញព័ត៌មាននិងការប្រើប្រាស់ផ្សេងៗទៀត

*សេចក្ដីប្រកាសប្រាប់ឲ្យដឹង*

- យើងអាចបញ្ចេញព័ត៌មានអំពីលោកអ្នកដើម្បីជួយនៅក្នុងការខំប្រឹងប្រែងផ្ដល់ជំនួយសំរាប់ពេលមានមហន្តរាយ។

*យើងអាចប្រើប្រាស់និងបញ្ចេញព័ត៌មានអំពីសុខភាពរបស់លោកអ្នកដែលនៅក្រោមការការពារសំរាប់ប្រយោជន៍ដល់កិច្ចការដូចខាងក្រោមនេះ:*

- ការបញ្ចេញព័ត៌មានដែលតម្រូវឲ្យធ្វើទៅតាមច្បាប់។
- សំរាប់ការត្រួតពិនិត្យមើលសកម្មភាពផ្សេងៗខាងការថែទាំសុខភាព។
- ក្នុងគោលបំណងធ្វើឲ្យមានសុខមាលភាពនិងសន្តិសុខដល់សាធារណៈជនដូចបានអនុញ្ញាត្តិឬតម្រូវទៅតាមច្បាប់។
- ដើម្បីរាយការអំពីការសង្ស័យថាមានការប្រមាថឬការមិនយកចិត្តទុកដាក់។
- សំរាប់កិច្ចការនៅក្នុងទម្រង់ការនៃតុលាការ/ទម្រង់ការអភិបាល។
- សំរាប់ប្រយោជន៍ខាងផ្នែកនគរបាលដូចបានអនុញ្ញាតឬតម្រូវទៅតាមច្បាប់។
- សំរាប់ក្រសួងពន្ធនាគារ បើសិនលោកអ្នកនៅក្នុងមន្ទីរឃុំឃាំងឬក្រសួងពន្ធនាគារ ដែលជាការចាំបាច់សំរាប់ជាប្រយោជន៍សុខភាពរបស់លោកអ្នកនិងសុខភាពនិងសន្តិសុខរបស់អ្នកដទៃទៀត។
- សំរាប់ពិធីពិសេសរបស់រដ្ឋាភិបាលនិងការសងប្រាក់ដល់កម្មករដែលទទួលគ្រោះថ្នាក់នៅកន្លែងធ្វើការ។
- សំរាប់សកម្មភាពខាងធ្វើការស្រាវជ្រាវដែលទទួលការយល់ព្រម។
- ចំពោះអ្នកធ្វើសពវិភាគ, គ្រូពេទ្យពិនិត្យមើលសព, ឬ អ្នកចាត់ចែងកន្លែងបុណ្យសព។

## ការប្រើប្រាស់ផ្សេងៗទៀត

- ការប្រើប្រាស់និងការបញ្ចេញព័ត៌មានដែលមិនមានពិពណ៌នានៅក្នុងសេចក្ដីប្រកាសនេះនឹងធ្វើទៅបានលុះណាតែច្បាប់អនុញ្ញាតឲ្យធ្វើតែប៉ុណ្ណោះ ឬដោយមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីលោកអ្នក។

## IV ដើម្បីសុំជំនួយឬធ្វើការតវ៉ា

បើលោកអ្នកមានសំនួរ, ចង់បានព័ត៌មានបន្ថែម ឬចង់រាយការអំពីបញ្ហាមួយដែលទាក់ទងនឹងការរក្សាទុកព័ត៌មានរបស់លោកអ្នក ។អាចទាក់ទងមកភ្នាក់ងាររក្សាជាភាពឯកជន/សម្ងាត់ នៅលេខ ២០៦-២៩៦-៥២១៣។

បើសិនលោកអ្នកយល់ថាសិទ្ធិរក្សាជាភាពឯកជន/សម្ងាត់របស់លោកអ្នកត្រូវបានគេបំពានទៅលើ លោកអ្នកអាចបញ្ជូនការតវ៉ាជាលាយលក្ខណ៍អក្សរទៅភ្នាក់ងាររក្សាជាភាពឯកជន/សម្ងាត់ នៅអាស័យដ្ឋានលេខ 401 Fifth Avenue, Suite 400, Seattle, WA 98104 លោកអ្នកក៏អាចដាក់ពាក្យតវ៉ាជាលាយលក្ខណ៍អក្សរទៅលេខាធិការប្រចាំសហរដ្ឋអាមេរិកនៃក្រសួងសុខមាលភាពនិងមនុស្សកិច្ច។

*យើងគោរពដល់សិទ្ធិរបស់លោកអ្នកក្នុងការផ្ញើសេចក្ដីតវ៉ាមកយើងឬទៅលេខាធិការនៃក្រសួងសុខមាលភាពនិងមនុស្សកិច្ច។ បើសិនលោកអ្នកជ្រើសរើសយកធ្វើពាក្យបណ្ដឹងនេះ យើងនឹងមិនធ្វើការរករឿងសងសឹកនឹងលោកអ្នកឡើយ។*

## បណ្ដាញនៃការទាក់ទងតាមកុំព្យូទ័រ Website

- យើងមានបណ្ដាញនៃការទាក់ទងតាមកុំព្យូទ័រ ដែលផ្ដល់នូវព័ត៌មានអំពីយើង។ សំរាប់ជាប្រយោជន៍ដល់លោកអ្នកសេចក្ដីប្រកាសនេះមាននៅក្នុងបណ្ដាញនៃការទាក់ទងតាមកុំព្យូទ័រដែលមានអាស័យដ្ឋានលេខ: www.kingcounty.gov/healthServices/MHSA